ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៩០០ សហវ.អលក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៧

## សូមគោរពជូន
## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

**កម្មវត្ថុ:** ករណីសំណើសុំពិនិត្យ និងសម្រេចប្រគល់កិច្ចសន្យាជូន**ក្រុមហ៊ុន គង់ ហុង** ដើម្បីផ្គត់ផ្គង់ឯកសណ្ឋាន និងសម្ភារផ្គត់ផ្គង់ផ្សេងៗរបបប្រើប្រាស់ ឆ្នាំ២០១៧ ជូនក្រសួងការពារជាតិ ។

**យោង:** -លិខិតលេខ ៦៦៩ សហវ.អថ ចុះថ្ងៃទី០៣ ខែកុម្ភៈឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-កំណត់ហេតុបើកឯកសារដេញថ្លៃ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ របស់ គ.ល ក្រសួងការពារជាតិ
-កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា និងកំណត់ហេតុប្រជុំចរចាបញ្ចុះថ្លៃចុះថ្ងៃទី១៨ខែឧសភា ឆ្នាំ២០១៧ របស់ គ.ល ក្រសួងការពារជាតិ
-លិខិតលេខ ៣៨៦/សណ/២០១៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងការពារជាតិ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងការពារជាតិ ក្នុងការប្រគល់កិច្ចសន្យាជូន **ក្រុមហ៊ុន គង់ ហុង** ដើម្បីផ្គត់ផ្គង់ឯកសណ្ឋាន និងសម្ភារផ្គត់ផ្គង់ផ្សេងៗរបបប្រើប្រាស់ឆ្នាំ២០១៧ ដែលមានតម្លៃទឹកប្រាក់សរុបចំនួន **៥៥.៩១៣.១៧០.៧៥០រៀល (ហាសិបប្រាំប៊ីលាន ប្រាំបួនរយដប់បីលាន មួយរយចិតសិបពាន់ ប្រាំពីររយហាសិបរៀលគត់)** ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន
-អគ្គនាយកដ្ឋានពន្ធដារ
-អគ្គនាយកដ្ឋានថវិកា
-ក្រុមហ៊ុន គង់ ហុង
-ឯកសារ-កាលប្បវត្តិ